វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប
Prek Leap National Institute Of Agriculture

# វិទ្យាសាស្ត្រដំណាំ



រៀបរៀងដោយ៖ បណ្ឌិត ឈុន តួរី

# មាតិកា

**បុព្វកថា**
**សេចក្ដីផ្ដើម** ........ ៨
**ជំពូកទី១ ដំណាំស្មៀង** ........ ៩
១.១ ដំណាំយកគ្រាប់ ........ ៩
១.២ ពពួកសណ្ដែក ........ ១០
១.៣ គ្រាប់ពូជ និងគ្រាប់ផ្លែ ........ ១២
១.៤ បន្លែ ........ ១៥
**ជំពូកទី២ ដំណាំចំណីសត្វ** ........ ១៧
២.១ សណ្ដែកAlfaba ........ ១៧
២.២.ចកបាយទា(Common duckweed) ........ ១៨
២.៣ ចកអាសូឡា (Azolla) ........ ២០
២.៤ ស្មៅSorghum-Sudan ........ ២២
**ជំពូកទី៣ កត្តាបរិស្ថានលើការលូតលាស់ និងទិន្នផលដំណាំ** ........ ២៧
៣.១ កត្តាមានជីវិត ........ ២៧
៣.២ កត្តាគ្មានជីវិត ........ ២៨
**ជំពូកទី៤ ការអនុវត្តក្នុងការដាំដុះដំណាំ** ........ ៣២
៤.១ ការជ្រើសរើសទីកន្លែង ពូជ និងប្រភេទផ្សេងៗ ........ ៣២
៤.២ ការអនុវត្តចម្រុះ ........ ៣៣
៤.២.១ ដំណាំបង្វិល ........ ៣៣
៤.២.២ ដំណាំគំរប ........ ៣៤
៤.២.៣ ដំណាំចម្រុះ ........ ៣៤
៤.២.៤ ការរួមបញ្ចូលគ្នា នៃដាំដំណាំ និងចិញ្ចឹមសត្វ ........ ៣៥
៤.៣ ការគ្រប់គ្រងដី ........ ៣៦
៤.៤ ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព ........ ៣៦
៤.៤.១ ប្រព័ន្ធស្រោចស្រពដោយផ្ទៃខាងលើ ........ ៣៧
៤.៤.២ ប្រព័ន្ធដំណក់ទឹក ........ ៣៨
៤.៤.៣ ប្រព័ន្ធស្រោចស្រពដោយបាចសាចឬក្បាលវិល ........ ៣៩
៤.៤.៤ ប្រព័ន្ធស្រោចស្រពដោយបង្កប់ទុយោក្រោមដី ........ ៤០
៤.៥ ការគ្រប់គ្រងសារធាតុចិញ្ចឹម ........ ៤១
៤.៥.១ ប្រភពនៃសារធាតុចិញ្ចឹមរុក្ខជាតិ ........ ៤២

៤.៥.២ ការប្រើប្រាស់ដី ........................................................................ ៤៣
៤.៥.៣ កង្វះសារធាតុចិញ្ចឹមនៅក្នុងរុក្ខជាតិ ..................................................... ៤៤
៤.៦ វិធានការចម្រុះគ្រប់គ្រងសត្វល្អិតចង្រៃ ........................................................ ៤៥
៤.៦.១ វិធានការជីវសាស្រ្ត ................................................................... ៤៦
៤.៦.២ វិធានការដាំដុះ ........................................................................ ៤៧
៤.៦.៣ វិធានការមេកានិច និងវិធានការរូបសាស្រ្ត ............................................ ៤៧
៤.៦.៤ វិធានការគីមី ........................................................................... ៤៨
ឯកសារយោង

# បុព្វកថា

ដំណើរអភិវឌ្ឍន៍ នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែល សន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើងដើម្បីតម្រង់ ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយ មានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាង ហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅ វិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវ ជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគ ទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជន ពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុស

ត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២ នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ចពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយ ពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃ វិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជា ស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុង

ទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះ ដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និង ជាពិសេសគឺការបណ្ដុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើន ជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយ សំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាប់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្ដែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកា ឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំ ជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ និងផ្ដល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា
2. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និង និស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែ ច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន ៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម ៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ **រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា(Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើន បរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែល កំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀប រៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយ ពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# វិទ្យាសាស្ត្រដំណាំ

## សេចក្តីផ្តើម

**និយមន័យវិទ្យាសាស្ត្រដំណាំ:** វិទ្យាសាស្ត្រដំណាំគឺជា វិទ្យាសាស្ត្រសិក្សាពីដំណាំស្បៀង, ដំណាំចំណីសត្វ និងដំណាំសរសៃ និងកត្តាបរិស្ថានរបស់ដំណាំទាំងនោះ។ វាជាវិទ្យាសាស្ត្រទូលំទូលាយដែលរួមបញ្ចូល ការបង្កាត់ពូជសេណេទិច ផលិតកម្ម និងការគ្រប់គ្រង។

## ហេតុអ្វីវិទ្យាសាស្ត្រក្លាយជាមានសារៈសំខាន់?

វិទ្យាសាស្ត្រត្រូវបានគេវាយតម្លៃថាជាជំហានដ៏មានសារៈសំខាន់បំផុតនៃប្រវត្តិមនុស្សលោក ពេលដែលមនុស្សបានចាប់ផ្តើមតាំងទីលំនៅ និងដាំគ្រាប់ពូជជាលើកដំបូង។ នេះជាការចាប់ផ្តើមកសិកម្ម និងការប៉ុនប៉ងបង្កាត់ប្រភេទគ្រាប់ពូជថ្មីដែលនឹងផ្តល់ទិន្នផលខ្ពស់ជាង។ ចេញពីចំណុចរបស់យើងទាំងនេះ វាគឺជាជំហានដំបូងនៃការដាំដំណាំបែបទំនើប និងវិទ្យាសាស្ត្រដំណាំចំណីសត្វ។

សព្វថ្ងៃនេះយើងប្រឈមមុខនៃការកើនឡើងចំនួនប្រជាជន។ ដូចច្នេះការបង្កាត់ពូជថ្មីៗត្រូវការចាំបាច់ដែលអាចចិញ្ចឹមមនុស្សដែលចេះតែកើនឡើងនៅលើពិភពលោកនេះបាន។ម្យ៉ាងវិញទៀត គេអាចទទួលសមិទ្ធផលនេះបានតាមរយៈវិធីសាស្ត្របង្កាត់ដែលអាចផ្តល់ទិន្នផលខ្ពស់។ ទន្ទឹមនឹងនេះពូជថ្មីៗដែលកើតចេញពីការបង្កាត់ទាមទារអោយធន់ទ្រាំទៅនឹងកត្តាជាច្រើនដូចជា ភាពរាំងស្ងួត និងសីតុណ្ហភាពខ្ពស់ដែលយើងនឹងប្រឈមមុខក្នុងពេលខាងមុខដោយសារតែបម្រែបម្រួលអាកាសធាតុ។ ជាងនេះទៅទៀតជំងឺរុក្ខជាតិដែលបង្កដោយបាក់តេរី, ផ្សិត, សត្វល្អិត, វីរុស និងកត្តាចង្រៃដទៃទៀត អាចគំរាមគំហែងដល់កសិករជាពិសេសប្រសិនបើពួកគេដាំដំណាំក្នុងទ្រង់ទ្រាយជាលក្ខណៈឯកដំណាំ (Monocrop) ដោយកសិករភាគច្រើនយល់ឃើញថាបានផលចំណេញច្រើន។ វិទ្យាសាស្ត្រដំណាំអាចជួយដើម្បីកំណត់ និងបង្កើតពូជថ្មីដែលមានលក្ខណៈធន់ទ្រាំក៏អាចជួយកាត់បន្ថយការប្រើប្រាស់ថ្នាំពុលកសិកម្ម ដែលកសិករប្រើប្រាស់ដើម្បីរារាំងការបង្ករបស់កត្តាចង្រៃ។ ដូច្នេះវិទ្យាសាស្ត្រដំណាំមានអត្ថន័យទូលំទូលាយសម្រាប់ពិភពលោកយើងទាក់ទងទៅនឹងស្បៀងអាហារ និងបរិស្ថាន។

## ជំពូក១ ដំណាំស្បៀង

"ដំណាំស្បៀង" សំដៅលើ ការផ្គត់ផ្គង់អាហារសំខាន់ៗ របស់ពិភពលោកដែលផលិតចេញពីដំណាំតាមរយៈការធ្វើកសិកម្ម។ ដំណាំស្បៀងសំខាន់ៗរបស់ពិភពលោកដែលផលិតចេញពីដំណាំតាមរយៈការធ្វើកសិកម្ម។ ដំណាំស្បៀងសំខាន់ៗរួមមានដំណាំធុញ្ញជាតិ, ពពួកសណ្តែក, ដំណាំយកគ្រាប់, ដំណាំយកផ្លែ, ដំណាំតិណទេស (herb), ដំណាំសម្រាប់ផលិតភេសជ្ជៈដូចជាតែ និងកាហ្វេ។

### ១.១ ដំណាំយកគ្រាប់ (Grains)

គ្រាប់ដំណាំ ជាប្រភពសារធាតុចិញ្ចឹមយ៉ាងសំខាន់នៃស្បៀងអាហាររបស់មនុស្សមានដូចជាស្រូវ ស្រូវសាលី និងពោត ដែលជាប្រភពដំណាំយកគ្រាប់ដែលត្រូវបានគេបរិភោគច្រើនបំផុតនៅលើពិភពលោកយើងនេះ។ ស្រូវសាលី និងស្រូវជាប្រភពដែលសម្បូរប្រូតេអ៊ីនខ្ពស់ជាងគេបំផុត។

គ្រាប់ពូជដំណាំ គឺជាអាហារប្រចាំថ្ងៃរបស់មនុស្សច្រើនពាន់ឆ្នាំមកហើយ។ ជាពិសេសដំណាំស្រូវសាលីគឺជាប្រភេទដំណាំដែលអនុគ្រោះ និងលូតលាស់ល្អនៅបរិស្ថានសីតុណ្ហភាពត្រជាក់ ចំណែកឯស្រូវ និងពោតវិញដុះលូតលាស់ល្អនៅតំបន់ត្រូពិច និងត្រូពិចរង។ នៅក្នុងសម័យទំនើបបច្ចុប្បន្ននេះប្រទេសដែលសម្បូរទ្រព្យធនអាចបរិភោគអាហារដែលមានគ្រាប់ធុញ្ញជាតិច្រើនប្រភេទដែលគ្រាប់ធុញ្ញជាតិខ្លះធ្លាប់បានគេប្រើប្រាស់តែកន្លែងណាមួយប៉ុណ្ណោះ។ ប៉ុន្តែប្រទេសអ្នកមានទាំងនេះបានយកគ្រាប់ធុញ្ញជាតិទៅផ្តល់ជាចំណីសត្វដើម្បីផលិតសាច់សត្វ និងគ្រាប់ធុញ្ញជាតិសល់តិចតួចសម្រាប់បរិភោគជាអាហារពេលល្ងាច។




**រូបភាព១** ស្រូវ(រូបភាពឆ្វេង) និងស្រូវសាលី (រូបភាពស្តាំ)



**រូបភាព២** ពោត(រូបភាពឆ្វេង) និងSorghum (រូបភាពស្តាំ)

## ១.២ ពពួកសណ្តែក

វាជាប្រភេទអាហារប្រចាំថ្ងៃមួយផ្សេងទៀតនៅក្នុងប្រទេសជាច្រើននៅលើពិភពលោកយើងនេះ។ ជាទូទៅវាមានតម្លៃថោក ហើយវាអាចផ្គត់ផ្គង់ជាចំណីអាហារបានរយៈពេលវែងដែលធ្វើអោយវាមានលក្ខណៈសម្បត្តិល្អសម្រាប់រដូវកាលដែលដំណាំផ្សេងទៀតមិនសូវមាន។ ពពួកសណ្តែកសម្បូរទៅដោយកម្រិតប្រូតេអ៊ីនខ្ពស់ និងគុណភាពល្អ បើទោះបីជាវាមិនសូវមានរសជាតិឆ្ងាញ់ ហើយវាត្រូវបានគេប្រើប្រាស់ផ្សំជាមួយអាហារដទៃទៀតដើម្បីអោយរសជាតិឆ្ងាញ់។ ក្រៅពីប្រូតេអ៊ីន ពពួកសណ្តែកមានសារធាតុសរសៃកាបូនអ៊ីដ្រាត សារធាតុរ៉ែ និងវីតាមីន ដែលមានសារប្រយោជន៍យ៉ាងខ្លាំងចំពោះសារពាង្គកាយរបស់មនុស្ស។ ប៉ុន្តែពពួកសណ្តែកមិនមានវីតាមីនសេទេ បើគេមិនបរិភោគវាជាសណ្តែកបណ្តុះ។

អាហារដែលល្បីមួយដែលធ្វើពីសណ្តែកសៀងគឺ តូហ្វូ(Tofu) ឬគេហៅថា តៅហ៊ូ ដែលគេអាចប្រើប្រាស់កែច្នៃជាមួយអាហារជាច្រើនប្រភេទ។ បើទោះបីជាតៅហ៊ូមិនសូវមានរសជាតិពេលផ្សំជាមួយម្ហូបដទៃបង្កើតជារសជាតិឆ្ងាញ់។



**រូបភាព៣** សណ្តែកសៀង (រូបភាពឆ្វេង) និងសណ្តែកបាយ (រូបភាពស្តាំ)

 

**រូបភាព៤** សណ្តែកដី (រូបភាពឆ្វេង) និងសណ្តែកកួ (រូបភាពស្តាំ)

**តារាង១** បញ្ជីឈ្មោះពពួកសណ្តែកនិងឈ្មោះវិទ្យាសាស្ត្ររបស់វា

| **ឈ្មោះជាភាសាខ្មែរ (Common name)** | **ឈ្មោះវិទ្យាសាស្ត្រ(Scientific name)** |
|---|---|
| សណ្តែកដី (Peanut, ground-nut) | *Arachis hypogaea* |
| សណ្តែកក្រហម(Redgram, arhar) | *Cajanus cajan* |
| សណ្តែកអង្គុយ(Pigeon pea, yellow *dhal*, congo pea) | *Cajanus indicus* |
| សណ្តែកកូនមាន់(Chickpea, Bengal gram, garbanzo) | *Cicer arietinum* |
| - (Horse gram) | *Dolichos biflorus* |
| - (Lentil, masur *dhal)* | *Lens esculenta* |
| | *Lens culinaris* |
| | *Ervum lens* |
| សណ្តែកហ្វាបា(Broad bean, Windsor bean) | *Faba vulgaris* |
| សណ្តែកសៀង(Soybean) | *Glycine hispida* |
| | *Glycine max* |
| | *Glycine soja* |
| - (Lupin) | *Lupinus SPP* |
| (Velvet bean) | *Mucuna pruriens* |
| សណ្តែកបាយ(Mung bean, green gram) | *Phaseolus aureus golden gram* |
| | *Phaseolus radiatus* |
| | *Vigna radiate* |
| សណ្តែកលីម៉ា(Lima bean) | *Phaseolus lunatus* |
| សណ្តែកខ្មៅ(Black gram, mungo bean) | *Phaseolus mungo* |

| | |
|---|---|
| សណ្តែកក្រហមធំ(Kidney bean, navy bean, pinto bean) | |
| - (Haricot bean, snap bean) | *Phaseolus vulgaris* |
| សណ្តែកបារាំង(Pea) | *Pisum sativum* |
| ពពាយ(Winged bean) | *Tetragonolobus purpureus* |

**សំគាល់៖** - មិនទាន់ស្គាល់ឈ្មោះជាភាសាខ្មែរ។ ឈ្មោះនៅក្នុង ( ) ឈ្មោះជាភាសាអង់គ្លេស ឬឈ្មោះវិទ្យាសាស្ត្រ

### ១.៣ គ្រាប់ពូជ និងគ្រាប់ផ្លែ (Seed and nuts)

គ្រាប់ពូជ និងគ្រាប់ផ្លែដែលអាចប្រើប្រាស់ជាអាហារ គឺមានច្រើនប្រភេទណាស់។ ទាំងគ្រាប់ពូជ និងគ្រាប់ផ្លែគឺមានលក្ខណៈ Botanic ដូចគ្នាពីព្រោះពួកវាមានគ្រាប់ដែលមានទម្រង់អំប្រីយ៉ុង។ គ្រាប់ទាំងនេះជាប្រភពអាហារ និងមានថាមពលដ៏ខ្លាំង។



**រូបភាព៩** ប្រភេទគ្រាប់ពូជ និងគ្រាប់ផ្លែដែលផ្តល់ជាសុខភាពបំផុត



**រូបភាព៦** ផ្លែស្វាយចន្ទីនៅតំបន់ត្រូពិច(រូបភាពខាងឆ្វេង) និងផ្លែកៅឡាក់(រូបខាងស្តាំ)

**តារាង២** បញ្ជីឈ្មោះផ្លែគ្រាប់ពូជដែលដែលផ្តល់សុខភាពល្អបំផុតទាំង១០

| ឈ្មោះជាភាសាខ្មែរ (Common name) | ឈ្មោះវិទ្យាសាស្ត្រ | រូបភាព |
|---|---|---|
| គ្រាប់អាល់ម៉ុន (Almonds) | *Prunus amygdalus* |  |
| គ្រាប់សណ្តែកប្រេស៊ីល (Brazil nuts) | *Bertholletia excelsa* |  |
| គ្រាប់ស្វាយចន្ទី (Cashews) | *Anacardium occidentale* |  |
| គ្រាប់កៅឡាក់ (Chestnuts) | *Castanea sativa* |  |
| -(Hazelnuts) | *Corylus avellana* |  |
| គ្រាប់ម៉ាកាដាមៀ(Macadamia nuts) | *Macadamia integrifolia* |  |
| គ្រាប់ភីខាន(Pecans) | *Carya illinoinensis* |  |
| គ្រាប់ស្រល់(Pine nuts) | *Pinus gerardiana* |  |
| គ្រាប់រីវាយ(Pistachios) | *Pistacia vera* |  |
| គ្រាប់ខួរក្បាល(Walnuts) | *Juglans regia* |  |

**សំគាល់៖** - មិនទាន់ស្គាល់ឈ្មោះជាភាសាខ្មែរ ( ) ឈ្មោះជាភាសាអង់គ្លេស

### ១.៤ បន្លែ (Vegetables)

បន្លែគឺជាប្រភពវីតាមីន សារធាតុរ៉ែ និងសារធាតុដែលមិនធ្វើអោយធាត់សម្រាប់មនុស្ស។ បន្លែស្លឹកជាពិសេសមានសារៈសំខាន់ ពីព្រោះវាមានផ្ទុកសារធាតុចិញ្ចឹម ចំណែកបន្លែយកឬសផ្ទុកទៅដោយអាមីដុង និងស្ករធម្មជាតិដែលផ្តល់ថាមពលដល់មនុស្ស។

បន្លែត្រូវបានគេដាំជាលក្ខណៈពាណិជ្ជកម្ម និងដាំក្នុងសួនផ្ទះ ឬជាដំណាំសម្រាប់សុខភាព។ បន្លែសរីរាង្គមានតម្លៃថ្លៃជាង ហើយមានសារធាតុចិញ្ចឹមខ្ពស់ជាងបន្លែដែលដាំដោយប្រើប្រាស់សារធាតុគីមី។ ទន្ទឹមនឹងនេះបន្លែសរីរាង្គក៏មានរសជាតិប្រសើរជាងបន្លែដែលប្រើប្រាស់គីមីផងដែរ។



**រូបភាព១៤** ពពួកបន្លែយកស្លឹក

**តារាង៣** បញ្ជីឈ្មោះបន្លែដែលផ្តល់សុខភាពល្អបំផុត

| ឈ្មោះជាភាសាខ្មែរ (Common name) | ឈ្មោះវិទ្យាសាស្ត្រ (Scientific name) | រូបភាព |
|---|---|---|
| ស្ពៃស្ពីណាច(Spinach) | *Spinacia oleracea* |  |
| កាត់ណាបារាំង (Kale) | *Brassica oleracea* |  |
| ខាត់ណាផ្កា (Broccoli) | *Brassica oleracea* |  |
| សណ្តែកខៀវ (Peas) | *Pisum sativum* |  |
| ដំឡូងជ្វា(Sweat potatoes) | *Ipomoea batatas* |  |
| ស្ពៃមើម (Beet) | *Beta vulgaris* |  |
| ការ៉ុត (Carrot) | *Daucus carota* |  |
| ប៉េងប៉ោះ (Tomatoes) | *Solanum lycopersicum* |  |
| ខ្ទឹមស (Garlic) | *Allium sativum* |  |
| ខ្ទឹមបារាំង(Onions) | *Allium cepa* |  |

**សំគាល់៖** - មិនទាន់ស្គាល់ឈ្មោះជាភាសាខ្មែរ។ ឈ្មោះនៅក្នុង ( ) ឈ្មោះជាភាសាអង់គ្លេស ឬឈ្មោះវិទ្យាសាស្ត្រ

# ជំពូក ២ ដំណាំចំណីសត្វ

ដំណាំចំណីសត្វ គឺជាចំណីដែលបានមកពីដំណាំកសិកម្មដែលត្រូវបានគេប្រើប្រាស់ដើម្បីផ្តល់ជាចំណីដល់សត្វមានដូចជាៈ សត្វពាហនៈ បក្សី ជ្រូក ទន្សាយ ឆ្កែ ឆ្មា។ល។ ចំណីសត្វរួមមាន ផ្អកស្មៅឬសត្វរុក្ខជាតិ, ចំប៉ើង Silage ចំណីគ្រាប់, ចំណីលាយ, គ្រាប់ពូជ(ដូចជាគ្រាប់ពូជសណ្តែកបណ្តុះ)។ ចំណីសត្វភាគច្រើនផលិតចេញពីរុក្ខជាតិ ឬដំណាំ ប៉ុន្តែអ្នកផលិតមួយចំនួនដាក់បន្ថែមសារធាតុចិញ្ចឹមដើម្បីកែច្នៃជាចំណីដែលមានប្រភពដើមជាសត្វ។

ការធ្វើពាណិជ្ជកម្មចំណីសត្វមានបរិមាណ 873លានតោន នៅក្នុងឆ្នាំ 2011 ដែលកើនយ៉ាងលឿនជិតដល់ 1000លានតោន យោងទៅតាមសហពន្ធ័ (http://www.ifif.org/pages/Global Feed Production)។ ជាមួយនឹងការកើនឡើងជាមធ្យមប្រចាំឆ្នាំ2%។ ការប្រើប្រាស់ដីកសិកម្មសម្រាប់ដាំដុះដំណាំចំណីសត្វជាជាងដាំដំណាំចំណីមនុស្សអាចជាបញ្ហាចម្រូងចម្រាស់។ ចំណីសត្វប្រភេទខ្លះ ដូចជាចំណីផលិតពីពោតក៏អាចជាចំណីសម្រាប់មនុស្សផងដែរ។ ចំពោះចំណីសត្វដូចជា ពពួកស្មៅអាចត្រូវបានគេដាំនៅលើដីដែលគេអាចប្រើប្រាស់សម្រាប់ដាំដំណាំសម្រាប់អាហារមនុស្ស។ ក្នុងករណីជាច្រើនផលិតកម្មដំណាំស្មៅសម្រាប់សត្វពាហនៈគឺធ្វើឡើងនៅចន្លោះដំណាំសម្រាប់អាហារមនុស្ស ពីព្រោះវាជួយបង្កើនសារធាតុសរីរាង្គក្នុងដី។ដំណាំចំណីសត្វសំខាន់ៗរួមមានដូចខាងក្រោម៖

## ២.១ សណ្តែក Alfaba (Medicago Sativa)

សណ្តែក Alfaba ឬ Lucerue ជាប្រភេទដំណាំយូរឆ្នាំស្ថិតនៅក្នុងគ្រួសារសណ្តែក ។ វាត្រូវបានគេធ្វើជាដំណាំចំណីសត្វយ៉ាងសំខាន់ៗក្នុងប្រទេសជាច្រើន។ សណ្តែកនេះត្រូវបានគេដាំជាវាលស្មៅសម្រាប់សត្វស៊ី ជាផ្អកស្មៅ ហើយក៏សម្រាប់ធ្វើជាជីបៃតង និងដំណាំគ្របដីផងដែរ។ ឈ្មោះថាសណ្តែក Alfaba នេះត្រូវបានគេប្រើនៅទ្វីបអាមេរិចខាងជើង។ ឈ្មោះ Lucerue គឺជាឈ្មោះមានលក្ខណៈទូលំទូលាយជាងដែលគេប្រើប្រាស់នៅក្នុងប្រទេសអង់គ្លេស អាព្រិចខាងត្បូង អូស្ត្រាលី និងញូហ្ស៊ីឡង់។ សណ្តែក Alfaba នេះមានលក្ខណៈស្រដៀងគ្នាទៅនឹងដើមចន្ទុលភ្នំ(Clover)ដែលស្ថិតនៅក្នុងគ្រួសារតែមួយលក្ខណៈស្រដៀងគ្នារវាងសណ្តែក Alfaba និងចន្ទុលភ្នំនេះកើតឡើងជាពិសេសពេលដើមនៅខ្ចីពេលស្លឹកមានទម្រង់ស្លឹកបីដែលមានរូបរាងមូល។ នៅដំណាក់កាលពេញវ័យផ្ទៃស្លឹកពន្លូតវែង។ វាមានផ្កាតូចពណ៌ស្វាយជាប់គ្នាជាចង្កោមបន្តបន្ទាប់ដោយផ្លែរមូលចូលគ្នា 2-3 ស្រទាប់ដែលមាន 10-20 គ្រាប់។ សណ្តែក Alfaba មានប្រភពចេញពីតំបន់ត្រជាក់បង្គួរ។ វាត្រូវបានដាំដុះដើម្បីធ្វើជាចំណីសត្វចាប់តាំងពីយ៉ាងហោចណាស់កាលពីសម័យបុរាណក្រិច និងរ៉ូម៉ាំង។ សណ្តែកបណ្តុះ Alfaba ជាអាហារពេញនិយមមួយនៅប្រទេសឥណ្ឌាប៉ែកខាងត្បូង។



**រូបភាព៥** សណ្តែក Alfaba (*Medicago sativa*)

**២.២ ចកបាយទា (Common duckweed)**

- **ឈ្មោះវិទ្យាសាស្ត្រ** Lemnoideae
- **រជ្ជ** Plantae
- **គ្រួសារ** Araceae
- **លំដាប់** Alismatales

ចកបាយទា គឺជាប្រភេទរុក្ខជាតិដែលដុះក្នុងទឹកស្ថិតនៅក្នុងគ្រួសារ Araceae ។ ចកបាយទា ត្រូវបានគេប្រើជាចំណីសត្វ ជាភ្នាក់ងារសម្អាតទឹក និងសម្រាប់ជីបៃតងដាក់ដំណាំ។

ចកបាយទា ជារុក្ខជាតិដុះអណ្តែតលើទឹកដែលស្លឹក 1, 2, 3 ឬ 4 ដែលប្រភេទនីមួយៗមានដុះឫសមួយនៅក្នុងទឹក។ នៅពេលដុះស្លឹកកាន់តែច្រើន វាបំបែកខ្លួនជាដើមថ្មី។ ឫសចកបាយទា មានប្រវែង 1-2cm , ស្លឹកមានរាងពងក្រពើមានប្រវែង 1-6mm និងទំហំ 0.5-5mm ហើយមានពណ៌បៃតងខ្ចីមានសរសៃរវែន 3 (ករណីកម្រមាន 5 )និងមានបំពង់ខ្យល់ដែរអាចអោយដើមចកអណ្តែតលើផ្ទៃទឹកបាន។ វាបន្តពូជជាសំខាន់ដោយសរីរាង្គលូតលាស់តាមរយៈការបែកបង្កើនដើម។ វាកម្រចេញផ្កាណាស់ បើចេញផ្កាមានអង្គត់ផ្ចិត

ប្រហែល 1mm ដែលមានរាងជាពែងដែលមានអូវុលមួយ និង Stamen ពីរ។ គ្រាប់ចកបាយទាមានប្រវែង 1mm រុំពន្ធ័ដោយ 8-15 ស្រទាប់។ បក្សីមានតួនាទីសំខាន់ណាស់ក្នុងការពាំនាំគ្រាប់ចកនេះទៅកន្លែងថ្មី។ ឬសចកដែលស្អិតអាចធ្វើអោយដើមរបស់វាតោងជាប់ទៅនឹងរោម ឬជើងរបស់បក្សីហើយអាចទៅរកបឹងត្រពាំងថ្មី។

យោងទៅតាមឯកសារស្រាវជ្រាវ ទិន្នផលចកបាយទាប្រែប្រួលទៅតាមលក្ខខណ្ឌលូតលាស់ និងរដូវកាល។ ក្នុងលក្ខខណ្ឌល្អគេអាចទទួលទិន្នផលបាន 73 តោនម៉ាស់ស្ងួតក្នុងមួយហិចតា (Leng, 1999)។ ចកបាយទា មានកម្រិតប្រូតេអ៊ីនខ្ពស់ដែលប្រែប្រួលពី 20-40% អាស្រ័យទៅតាមរដូវកាលសារធាតុចិញ្ចឹមនៅក្នុងទឹក និងលក្ខខណ្ឌបរិស្ថាន។ ដោយសារចកបាយទាមិនមានជាលិកាលូតលាស់ស្មុគស្មាញ ដូច្នេះវាមានសារធាតុសរសៃរតិចជាង 5%។ ជាទូទៅគេអាចប្រើប្រាស់ចកបាយទាជាចំណីសម្រាប់ត្រី និងបក្សី ហើយចកបាយទាជាអាហារបំប៉នដ៏មានប្រយោជន៍។ លទ្ធផលពិសោធន៍ស្រាវជ្រាវបានបង្ហាញថា គេអាចប្រើចកបាយទាជំនួសទាំងស្រុង សណ្តែកសៀង ចំពោះចំណីទា។ គេអាចដាំចកប្រភេទនេះដោយផ្ទាល់នៅក្នុងកសិដ្ឋានដែលចំណាយថវិកាតិចបំផុត។ ដូច្នេះការប្រើប្រាស់ចកបាយទាជាអាហារសម្រាប់ការចិញ្ចឹមមាន់យកសាច់គឺចំណេញផ្នែកសេដ្ឋកិច្ច (Men et al.,2001)។ ការស្រាវជ្រាវបានបង្ហាញថា ចំណីផលិតពីប្រេងល្ងដែលមានតម្លៃថ្លៃអាចជំនួសខ្លះៗដោយប្រើប្រាស់ចកបាយទា។ ទោះជាយ៉ាងនេះក្តីដោយសារតែប្រូតេអ៊ីនដែលអាចរំលាយអាហារមានកម្រិតទាបនៅក្នុងចកបាយទា (68.9 ភាគរយ ប្រៀបធៀបជាមួយប្រេងល្ងមាន 89.9 ភាគរយ) ដូច្នេះគេអាចប្រើចកបាយទាសម្រាប់តែចំណីបំប៉នសម្រាប់មាន់ប៉ុណ្ណោះ (Ahammad et al., 2003) ។



**រូបភាព៦** ចកបាយទា Duckweed (*Lemnoideae*)

## ២.៣ ចកអាសូឡា (Azolla)

- **ឈ្មោះវិទ្យាសាស្ត្រ** Azolla caroliniana
- **រជ្ជ** Plantae
- **គ្រួសារ** Salviniaceae
- **លំដាប់** Salviniales



**រូបភាព ៧** ចកAzolla (Azolla caroliniana)

ចក Azolla ដែលគេអាចហៅជាភាសាអង់គ្លេសថា **mosquito fern**, **duckweed fern**, **fairy moss**, **water fern** ជារុក្ខជាតិដុះក្នុងទឹកដែលស្ថិតក្នុងអំបូរដែលរុក្ខជាតិ ៧ ប្រភេទ ផ្សេងគ្នា និងស្ថិតនៅក្នុងគ្រួសារ *Salviniaceae*។ ចក Azolla នេះមានទម្រង់ស្លឹកតូច និងមានរូបរាងច្បាស់លាស់ខុសពីពពួកចកដ៏ទៃទៀត ប៉ុន្តែស្រដៀងគ្នាទៅនឹងចកបាយទា និងពពួក Moss មួយចំនួន។ ចក *Azolla filiculoides* ជាប្រភេទមួយក្នុងចំណោមបណង្គជាតិ២ប្រភេទដែលគេបានបោះពុម្ពពីសេណូម(Genome)របស់វាកាលពីពេលថ្មីនេះ (Li et al., 2018)។ ចក Azolla ត្រូវបានគេចាត់ទុកថាជាប្រភេទរុក្ខជាតិឈ្លានពាន ក្នុងតំបន់ដីសើម បឹងទឹកសាប និងនៅក្នុងស្នាមភ្លោះប្រឡាយ។ ចក Azolla នេះអាចធ្វើឲ្យមានការផ្លាស់ប្តូរប្រព័ន្ធបរិស្ថានជលជាតិ និងជីវចម្រុះយ៉ាងសម្បើម (Weber, 2017) ។

### អត្ថប្រយោជន៍ចំពោះចំណីសត្វ

ក្រៅពីអត្ថប្រយោជន៍សម្រាប់ធ្វីជីសរីរាង្គសម្រាប់ដាក់ដំណាំ ចក Azollaត្រូវបានគេប្រើប្រាស់ផងដែរសម្រាប់ចំណីសត្វយ៉ាងមានប្រសិទ្ធភាព និងនិរន្តន៍រភាព (Pillai et al., 2008)។ ចក Azolla សម្បូរទៅដោយ ប្រូតេអ៊ីន អាមីណូអាស៊ីតសំខាន់ៗ វីតាមីន និងសារធាតុរ៉ែ។ ការសិក្សាបានបង្ហាញថា ការប្រើប្រាស់ ចក Azolla ផ្តល់ជាចំណីទៅឲ្យគោទឹកដោះ ជ្រូក ទា និងមាន់ ធ្វើឲ្យមានការកើនឡើងទិន្នផលទឹកដោះគោ

បរិមាណ និងទំងន់ស៊ុត បើប្រៀបធៀបជាមួយការចិញ្ចឹមតាមបែបប្រពៃណី។ ការសិក្សារបស់អង្គការស្បៀងអាហារ និងកសិកម្ម FAO បានពិពណ៌នាពីការដែល ចក Azolla បានធ្វើសមាហរ័ណកម្មខ្លួន ទៅក្នុងប្រព័ន្ធកសិកម្មជីវម៉ាស់តំបន់ត្រូពិច ដែលជួយកាត់បន្ថយធាតុនាំចូល (Inputs)( Preston and Murgueitio, 2011)។ មានការបារម្ភអំពីសារធាតុពុលនៅក្នុងAzollaពីព្រោះវាអាចផ្ទុកសារធាតុពុល **β-Methylamino-L-alanine** (BMAA) ហើយមានវត្តមាននៅក្នុងសារពាង្គកាយសត្វនៅពេលដែលសត្វស៊ី Azolla ជាចំណី ហើយសារធាតុ BMAA ត្រូវបានគេសង្ស័យថាអាចនាំទៅសារពាង្គកាយដ៏ទៃទៀតតាមរយៈច្រវ៉ាក់អាហារ (Banack et al., 2003)។ ចក Azolla ប្រហែលជាផ្ទុកសារធាតុ BMAA ដែលជាមូលហេតុបង្កជម្ងឺ neurodegenerative (Erik, 2015; McAuliffe, 2019; Bennett, 2019) ។ ចក Azolla ត្រូវបានគេធ្វើអានុសាសន៍សម្រាប់ជាអាហារសម្រាប់មនុស្ស ក៏ប៉ុន្តែមកទល់ពេលនេះមិនទាន់មានការសិក្សាពីសុវត្ថិភាពក្នុងការបរិភោគ Azolla នៅឡើយទេ (Erik, 2012)។



**រូបភាព៨** ប្រភេទចក Azolla ផ្សេងៗ

### ២.៤ ស្មៅ Sorghum-Sudan

- **ឈ្មោះវិទ្យាសាស្ត្រ** **Sorghum × drummondii**
- **រជ្ជ** Plantae
- **គ្រួសារ** Poaceae
- **លំដាប់** Poales



**រូបភាព៩** ស្មៅអ៊ីប្រីត Sorghum-Sudan

ស្មៅ Sorghum-Sudan គឺជាពូជស្មៅអ៊ីប្រីតដែលអាចដុះលូតលាស់នៅតំបន់ដែលមានសីតុណ្ហភាពក្តៅល្មមបាន។ មិនដូចប្រភេទស្មៅចំណីសត្វទៀតភាគច្រើនដែលដុះលូតលាស់ល្អនៅតំបន់ត្រជាក់។ អ៊ីប្រីត ដែលកើតចេញពីការបង្កាត់រវាង Sorghum និងស្មៅ Sudan ដែលត្រូវបានគេប្រើប្រាស់ជារឿយៗនៅក្នុងរដ្ឋ Ontario មជ្ឈមបូព៌ានៃប្រទេសកាណាដា។ ពូជស្មៅអ៊ីប្រីតអាចមានលក្ខណៈទៅនឹងមេបាណាមួយ ដូច្នេះកុំភ្លេចពិភាក្សានូវអ្វីដែលអ្នកចង់បានពីពូជអ៊ីប្រីតនេះ ជាមួយអ្នកលក់គ្រាប់ពូជមកអោយអ្នក។ Sorghum ត្រូវបានគេស្គាល់ថាជាពូជដែលធន់ទៅនឹងភាពរាំងស្ងួត។ វាមានប្រសិទ្ធិភាពទៅក្នុងការស្រូបយកទឹកពីព្រោះវាមានឬសទី២ ច្រើនជាងដំណាំពោតដល់ទៅ ២ដង ហើយមានផ្ទៃស្លឹកតិចជាងដំណាំពោតដល់ទៅពាក់កណ្តាលសម្រាប់រំហួតទឹកចេញ។ តម្រូវការទឹករបស់ Sorghum មានកម្រិតប្រហាក់ប្រហែលគ្នាទៅនឹងពោតដែរ ប៉ុន្តែ Sorghum មានសមត្ថភាពធន់ទ្រាំខ្លាំងជាងពោតក្នុងកំឡុងពេលខ្វះខាតទឹកយូរ។ ការលូតលាស់នឹងចាប់ផ្តើមពេលភ្លៀងចាប់ផ្តើម។

Sorghum-Sudan ផ្តល់ទិន្នផលទាបជាងដំណាំពោតបន្តិចប្រសិនបើគេប្រមូលផលសម្រាប់ចំណីសត្វ ប៉ុន្តែស្មៅ Sorghum-Sudan មានគុណសម្បត្តល្អម្យ៉ាងដោយសារតែគេអាចប្រមូលផលបាន ២-៣ ក្នុងមួយរដូវ ហើយគេស្តុកវាដោយកាត់ខ្លីៗ ឬរុំជារមូល។ ចំណីសត្វដែលបានមកពីពោត ផ្តល់ទំងន់ធ្ងន់ជាងក្នុងមួយហិចតា។ គេអាចប្រមូលផលស្មៅ Sorghum-Sudan ដោយប្រើប្រាស់ប្រពន្ធ័ដាំស្មៅឆ្លុតៗ។ ដូច្នេះគេអាចប្រមូលផលដោយប្រើប្រាស់បច្ចេកទេសផ្សេងៗសម្រាប់ Sorghum-Sudan ជាងដំណាំពោត។ សម្ភារៈឧបករណ៍ប្រមូលផល និងតម្រូវការចំពោះដំណាំចំណីសត្វនឹងជួយអោយសម្រេចចិត្តរវាង Sorghum-Sudan និងពពួកដំណាំចំណីសត្វប្រចាំឆ្នាំដទៃទៀត។

មានប្រភេទដំណាំចំណីសត្វបីប្រភេទផ្សេងគ្នានៅលើទីផ្សារដែលរួមមាន៖

១. ស្មៅ Sorghum៖ ពូជ Sorghum និងអ៊ីប្រ៊ីតមានដើមរសជាតិផ្អែម។ វាផ្តល់ទិន្នផលទាបជាងពូជស្មៅអ៊ីប្រ៊ីត Sudan ហើយដុះឡើងវិញមានសន្ទុះយឺត។

២. ស្មៅ Sudan៖ មានដើមតូច សម្បូរស្លឹក ហើយដុះលូតលាស់លឿន។ ស្មៅនេះត្រូវបានគេដាំដើម្បីឃ្វាលសត្វអោយស៊ី ឬគេអាចប្រើប្រាស់ប្រពន្ធ័ចម្រុះក្នុងការប្រមូលផល ឬកាត់វា។ ប្រសិនបើគេកាត់វាដោយប្រើប្រាស់ប្រពន្ធ័តែមួយទិន្នផលរបស់ស្មៅ Sudan នឹងតិចជាងស្មៅ Sorghum ។ គុណភាពស្មៅ Sudan មានកម្រិតខ្ពស់ជាង Sorghum ដោយសារតែវាមានសារធាតុសរសៃរប្រសិនបើកាត់វាជារឿយៗ។

៣. ស្មៅអ៊ីប្រ៊ីត Sorghum-Sudan វាជាប្រភេទស្មៅដែលគេនិយមដាំជាងគេ។ វាមានដើមធំ ស្លឹកតិចជាង Sudan ប៉ុន្តែដុះល្អនៅក្នុងលក្ខខណ្ឌអាកាសធាតុប្រទេសកាណាដា។

**ប្រុងប្រយ័ត្ន:**

សមាជិកគ្រួសាររបស់ស្មៅ Sorghum មានផ្ទុកសារធាតុ dhurrin គឺជា glucoside មួយដែលបំបែកដើម្បីបញ្ចេញអាស៊ីត Hydrocyanic ដែលគេស្គាល់ផងដែរថាជាអាស៊ីត Prussic ។ ការរារាំងការលូតលាស់ភ្លាមៗដូចជាភាពត្រជាក់ ភាពរាំងស្ងួត ឬការកាត់ស្មៅ Sorghum ធ្វើអោយមានការបញ្ចេញអាស៊ីត Prussic នៅក្នុងដើមនៅក្នុងកម្រិតខ្ពស់។ កម្រិតខ្ពស់អាស៊ីត Prussic អាចបណ្តាលអោយសត្វដែលស៊ីស្មៅ Sorghum នេះស្លាប់បាន។ អាស៊ីត Prussic នឹងថមថយក្នុងរយៈពេល១ទៅ២សប្តាហ៍ ដូច្នេះស្មៅស្រស់ដែលធ្វើជាស្មៅផ្អកមានសុវត្ថិភាពក្នុងការប្រើប្រាស់ជាចំណី។

**កូនស្មៅ:**

